ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# លក្ខន្តិកៈ

# សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នៃព្រះរាជាណាចក្រកម្ពុជា

Statute

National League of Associations of Municipal, District, Khan, Commune and Sangkat Councils

# មាតិកា

## លក្ខន្តិកៈ

## សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នៃព្រះរាជាណាចក្រកម្ពុជា


**បុព្វកថា**

**បេសកកម្ម និងគោលការណ៍គ្រឹះ**

បេសកកម្ម

គោលការណ៍គ្រឹះ

**ជំពូកទី១**

**បទប្បញ្ញត្តិទូទៅ**

មាត្រា ១ ឈ្មោះ

មាត្រា ២ វិសាលភាព និងការចូលជាធរមាន

មាត្រា ៣ ការធ្វើវិសោធនកម្មលក្ខន្តិកៈ

**ជំពូកទី ២**

**អាសយដ្ឋាន ត្រា និងរូបសញ្ញា**

មាត្រា ៤ អាសយដ្ឋាន

មាត្រា ៥ ត្រា និងរូបសញ្ញា

**ជំពូកទី ៣**

**គោលបំណង និងទិសដៅ**

មាត្រា ៦ គោលបំណង

មាត្រា ៧ ទិសដៅ

## ជំពូកទី ៤

## សមាជិកភាព

មាត្រា ៨ សមាសភាព

មាត្រា ៩ ការចូលជាសមាជិក

មាត្រា ១០ ការបាត់បង់សមាជិកភាព

មាត្រា ១១ ការចូលសមាជិកភាពសាជាថ្មី

## ជំពូកទី៥

## រចនាសម្ព័ន្ធ និងតួនាទី

មាត្រា ១២ រចនាសម្ព័ន្ធ

### មហាសន្និបាត

មាត្រា ១៣ ប្រតិភូមហាសន្និបាត

មាត្រា ១៤ ប្រធាន អនុប្រធានមហាសន្និបាត

មាត្រា ១៥ ការរៀបចំមហាសន្និបាត

មាត្រា ១៦ ភារកិច្ចរបស់មហាសន្និបាត

### ក្រុមប្រឹក្សាជាតិ

មាត្រា ១៧ សមាសភាព

មាត្រា ១៨ អាណត្តិរបស់ក្រុមប្រឹក្សាជាតិ

មាត្រា ១៩ កិច្ចប្រជុំរបស់ក្រុមប្រឹក្សាជាតិ

មាត្រា ២០ ភារកិច្ចរបស់ក្រុមប្រឹក្សាជាតិ

មាត្រា ២១ ភារកិច្ចរបស់ប្រធានក្រុមប្រឹក្សាជាតិ

### គណៈកម្មាធិការប្រតិបត្តិជាតិ

មាត្រា ២២ សមាសភាព

មាត្រា ២៣ អាណត្តិរបស់ប្រធានគណៈកម្មាធិការប្រតិបត្តិជាតិ

មាត្រា ២៤ កិច្ចប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិជាតិ

មាត្រា ២៥ ភារកិច្ចរបស់គណៈកម្មាធិការប្រតិបត្តិជាតិ

មាត្រា ២៦ ភារកិច្ចរបស់ប្រធានគណៈកម្មាធិការប្រតិបត្តិជាតិ

មាត្រា ២៧ គណៈកម្មការរបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់

### ថ្នាក់ដឹកនាំ

មាត្រា ២៨ សមាសភាព

មាត្រា ២៩ អាណត្តិរបស់ថ្នាក់ដឹកនាំ

មាត្រា ៣០ កិច្ចប្រជុំរបស់ថ្នាក់ដឹកនាំ

មាត្រា ៣១ ភារកិច្ចរបស់ថ្នាក់ដឹកនាំ

### អគ្គលេខាធិការដ្ឋានសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់

មាត្រា ៣២ អគ្គលេខាធិការដ្ឋាន

មាត្រា ៣៣ លក្ខណៈសម្បត្តិអគ្គលេខាធិការ

មាត្រា ៣៤ ភារកិច្ចរបស់អគ្គលេខាធិការ

មាត្រា ៣៥ អគ្គលេខាធិការរង

មាត្រា ៣៦ ក្រុមទីប្រឹក្សាគោលនយោបាយ

## ជំពូកទី៦

## ប្រាក់ចំណូល ចំណាយ និងកិច្ចការហិរញ្ញវត្ថុ

មាត្រា ៣៧ ប្រាក់សមាជិកភាពប្រចាំឆ្នាំ

មាត្រា ៣៨ ប្រភពចំណូលផ្សេងៗ របស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់

មាត្រា ៣៩ ការផ្ទេរចំណូល

មាត្រា ៤០ ការចំណាយ

មាត្រា ៤១ ក្រុមសវនកម្មរបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់

# លក្ខន្តិកៈ

# សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នៃព្រះរាជាណាចក្រកម្ពុជា

## បុព្វកថា

អនុលោមតាមស្មារតីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដូចមានចែងក្នុងជំពូកទី៣ មាត្រា៤២ ស្តីពីសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋក្នុងការបង្កើតសមាគម។

អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបានបង្កើតក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ តាមរយៈការបោះឆ្នោតដោយក្រុមប្រឹក្សាឃុំ សង្កាត់ ហើយច្បាប់នេះបានតម្រូវឲ្យក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ គាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់។

អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលបានបង្កើតក្រុមប្រឹក្សាឃុំ សង្កាត់ តាមរយៈការបោះឆ្នោតដោយប្រជាពលរដ្ឋផ្ទាល់។

ដោយហេតុថា ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់នៅកម្ពុជា មានការឯកភាព និងការប្តេជ្ញាចិត្តរួមគ្នាក្នុងការលើកកម្ពស់គុណភាពនៃជីវភាពរស់នៅ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ តាមរយៈអភិបាលកិច្ចតាមបែបវិមជ្ឈការ និងវិសហមជ្ឈការ។

ដោយហេតុថា ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ មានការប្តេជ្ញាចិត្តធានាជម្រុញការអភិវឌ្ឍសមត្ថភាពក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ជម្រុញការអភិវឌ្ឍ និងបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាជូនប្រជាពលរដ្ឋក្នុងមូលដ្ឋាន។

ដោយហេតុថា ជាការចាំបាច់ក្នុងការទទួលស្គាល់ និងបង្កើតអង្គការរួមមួយរបស់ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ដើម្បីជំរុញ និងកៀរគរក្រុមប្រឹក្សាឱ្យសម្រេចបានការប្តេជ្ញាចិត្តរួមទាំងនេះ។

ដោយហេតុថា ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ នៅកម្ពុជា បានបង្កើតសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នៅតាមរាជធានី ខេត្ត ហៅថាសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៅតាមរាជធានី ខេត្ត រួចហើយ។

ដូច្នេះ សមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់នៅតាមរាជធានី ខេត្ត រួមគ្នាបង្កើតសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដែលហៅថាសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៃព្រះរាជាណាចក្រកម្ពុជា។

## បេសកកម្ម និងគោលការណ៍គ្រឹះ

### បេសកកម្ម

សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ គឺជាស្ថាប័នធ្វើសកម្មភាពការងារក្នុងក្របខ័ណ្ឌសមាគមអព្យាក្រឹត្យ មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើសកម្មភាពបំរើឲ្យគណបក្សនយោបាយ មិនធ្វើជាឧបករណ៍ឲ្យគណបក្សនយោបាយ និងមិនស្វែងរកផលកម្រៃជាឯកជន។

សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ គឺជាស្ថាប័នដែលបង្កើតឡើងដោយការប្រមូលផ្តុំដោយស្ម័គ្រចិត្តរបស់សមាគមក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ និងធ្វើសកម្មភាពគ្មានកាលកំណត់ ដើម្បីការពារ និងបំរើផលប្រយោជន៍រួមរបស់សមាជិក។

### គោលការណ៍គ្រឹះ

សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ អនុវត្តតាមគោលការណ៍គ្រឹះមួយចំនួន ដូចខាងក្រោម៖

- គោលការណ៍ស្ម័គ្រចិត្ត
- គោលការណ៍ផ្តល់សិទ្ធិ និងឱកាសស្មើគ្នា
- គោលការណ៍តម្លាភាព
- គោលការណ៍សាមគ្គីភាព និងឯកភាពផ្ទៃក្នុង
- គោលការណ៍ឯករាជ្យភាព
- គោលការណ៍ប្រជាធិបតេយ្យ។

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.- ឈ្មោះ**

សមាគមនេះមានឈ្មោះថា "សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់" នៃព្រះរាជាណាចក្រកម្ពុជា ដែលហៅកាត់ថា សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ដោយសរសេរជាអក្សរបំព្រួញ ស.ក.ម និងមានឈ្មោះជាភាសាអង់គ្លេសថា "National League of Local Councils" ដោយសរសេរជាអក្សរបំព្រួញ "NLC" ។

## មាត្រា ២.- វិសាលភាព និងការចូលជាធរមាន

លក្ខន្តិកៈនេះ មានវិសាលភាពអនុវត្តក្នុងរង្វង់ក្របខ័ណ្ឌគោលនយោបាយ យុទ្ធ-សាស្ត្រនៃអាណត្តិរបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។

លក្ខន្តិកៈនេះ នឹងចូលជាធរមានបន្ទាប់ពីមានសេចក្តីសម្រេចរបស់មហាសន្និបាតសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។ សេចក្តីសម្រេចនេះត្រូវអនុម័តដោយការបោះឆ្នោតដែលមានសំឡេងគាំទ្រយ៉ាងតិចពីរភាគបីនៃចំនួនប្រតិភូពេញសិទ្ធិចូលរួមនៅក្នុងមហាសន្និបាត និងបន្ទាប់ពីបានចុះបញ្ជីតម្កល់សំណុំលិខិតនៅក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា។

សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ អាចធ្វើនិយត្តកម្ម ឬកែសម្រួលលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង គោលនយោបាយ និងនីតិវិធី ដោយផ្អែកតាមខ្លឹមសារគោលរបស់លក្ខន្តិកៈសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។

## មាត្រា ៣.- ការធ្វើវិសោធនកម្មលក្ខន្តិកៈ

លក្ខន្តិកៈនេះ អាចធ្វើវិសោធនកម្មបាន តាមសេចក្តីសម្រេចរបស់មហាសន្និបាត។ សេចក្តីសម្រេចនេះ ត្រូវធ្វើឡើងតាមការបោះឆ្នោតដែលសំឡេងគាំទ្រយ៉ាងតិចពីរភាគបីនៃចំនួនប្រតិភូពេញសិទ្ធិចូលរួមនៅក្នុងមហាសន្និបាត។

សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៅតាមរាជធានី ខេត្ត ដែលមានបំណងធ្វើវិសោធនកម្មលក្ខន្តិកៈនេះ ត្រូវដាក់សំណើជាលាយល័ក្ខណ៍អក្សរជូនសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ឱ្យបានយ៉ាងតិច ៦ខែ មុនថ្ងៃធ្វើមហា-សន្និបាត។

# ជំពូកទី២

# អាសយដ្ឋាន ត្រា និងរូបសញ្ញា

## មាត្រា ៤.- អាសយដ្ឋាន

សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មានអាសយដ្ឋាន និងការិយាល័យអចិន្ត្រៃយ៍នៅរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា។

អាសយដ្ឋាន និងការិយាល័យអចិន្ត្រៃយ៍នេះ អាចផ្លាស់ប្តូរបានតាមសេចក្តីសម្រេចរបស់ប្រធាន និងអនុប្រធានសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។

មាត្រា ៥.- ត្រា និងរូបសញ្ញា

សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវមានត្រា និងរូបសញ្ញាជាផ្លូវការរបស់ខ្លួន។

ត្រារបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មានរាងជារង្វង់មូលពីរជាន់។ រង្វង់ខាងក្រៅមានវិជ្ជមាត្រ ៣,៤ សង់ទីម៉ែត្រ និងរង្វង់ខាងក្នុងមានវិជ្ជមាត្រ ២,៨ សង់ទីម៉ែត្រ។ ផ្នែកខាងលើនៃរង្វង់ត្រា មានចារិកអក្សរខ្មែរថា ព្រះរាជាណាចក្រកម្ពុជា និងនៅផ្នែកខាងក្រោម មានចារិកអក្សរខ្មែរថា សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ហើយខ័ណ្ឌដោយផ្កាចាន់។ នៅចំណុចកណ្ដាលនៃត្រាមានរូបផែនទីនៃព្រះរាជាណាចក្រកម្ពុជា ហើយមានចារិកអក្សរថា "ស.ក.ម" ដោយមានអក្សរអង់គ្លេស "NLC" នៅពីក្រោម។

រូបសញ្ញារបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មានរូបផែនទីព្រះរាជាណាចក្រកម្ពុជា។ ក្នុងផែនទីមានរូបទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា ព័ទ្ធជារង្វង់ដោយកួរស្រូវពណ៌មាសភ្ជាប់ដោយខ្សែបូ អមដោយក្បាច់ភ្ញីវល្លិ៍ពណ៌មាស និងចារិកអក្សរថា "ស.ក.ម" ដោយមានអក្សរអង់គ្លេស "NLC" នៅពីក្រោម និងមានអក្សរជារង្វង់ស្នែងក្របីផ្នែកខាងក្នុងកួរស្រូវ សរសេរថា **សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់**នៃព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅលើផ្ទៃពណ៌បៃតង។

## ជំពូកទី៣

## គោលបំណង និងទិសដៅ

មាត្រា ៦.- គោលបំណង

គោលបំណងរបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ គឺ៖

- លើកកម្ពស់ឋានៈ និងអភិវឌ្ឍសមត្ថភាពរបស់ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់
- ការពារ និងស្វែងរកការគាំទ្រ ដើម្បីជាប្រយោជន៍ និងភាពស្របច្បាប់ជូនដល់សមាជិក
- លើកកម្ពស់ការចូលរួមអនុវត្តលទ្ធិប្រជាធិបតេយ្យ នៅថ្នាក់មូលដ្ឋានឲ្យមានប្រសិទ្ធភាព មាននិរន្តរភាព មានតម្លាភាព មានគណនេយ្យភាព និងមានភាពជាម្ចាស់

- កសាងភាពជាដៃគូជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ ដើម្បីអភិវឌ្ឍមូលដ្ឋាន រួមចំណែកក្នុងការពង្រឹងនីតិរដ្ឋ និងប្រជាធិបតេយ្យនៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៧.- ទិសដៅ**

ទិសដៅរបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ គឺដើម្បី៖

- ជួយក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដែលជាស្ថាប័នប្រជាធិបតេយ្យឲ្យមានការពឹងផ្អែកលើខ្លួនឯង និងមាននិរន្តរភាព
- ធ្វើឲ្យក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ឆ្លើយតបបានច្រើនចំពោះតម្រូវការជាពិសេស តម្រូវការរបស់ជនក្រីក្រ ស្ត្រី កុមារ និងក្រុមជនងាយរងគ្រោះ
- ផ្តល់ និងសម្របសម្រួលកម្មវិធីអភិវឌ្ឍន៍សមត្ថភាពដល់ក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន និងរួមសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ ដើម្បីរៀបចំការបណ្តុះបណ្តាល ការផ្លាស់ប្តូរបទពិសោធន៍ និងការផ្លាស់ប្តូរព័ត៌មាន
- ជម្រុញការសហការនៅក្នុងចំណោមក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ដើម្បីលើកកម្ពស់ និងសម្រេចបាននូវស្វ័យអភិបាលកិច្ចមូលដ្ឋានតាមបែបប្រជាធិបតេយ្យឲ្យមានប្រសិទ្ធភាពខ្ពស់
- ជម្រុញវប្បធម៌សហការ រៀនសូត្រ ចែករំលែកនៅក្នុងចំណោមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- លើកកម្ពស់ និងជម្រុញតួនាទីរបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៅតាមរាជធានី ខេត្ត ដែលជាអង្គការតំណាង និងពិគ្រោះយោបល់សម្រាប់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- បង្កើតច្រកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជាមួយសមាគមអាជ្ញាធរមូលដ្ឋាន និងស្ថាប័នដែលមានទស្សនៈដូចគ្នា នៅបរទេសសម្រាប់ការរៀនសូត្រ និងចែករំលែកបទពិសោធន៍ និងការគាំទ្រ
- តំណាង ការពារ និងតស៊ូមតិសម្រាប់ជាផលប្រយោជន៍ ដោះស្រាយកង្វល់ និងតម្រូវការរួមរបស់ក្រុមប្រឹក្សាថ្នាក់មូលដ្ឋានក្នុងការរៀបចំគោលនយោបាយ កម្មវិធី ច្បាប់ លិខិតបទដ្ឋាននៅថ្នាក់ជាតិ និងថ្នាក់រាជធានី ខេត្ត
- ទំនាក់ទំនង ពិគ្រោះយោបល់ និងរក្សាភាពជិតស្និទជាមួយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល គណបក្សនយោបាយ សមាជិកព្រឹទ្ធសភា រដ្ឋសភា អាជ្ញាធរ

មូលដ្ឋានជាតិ និងអន្តរជាតិលើបញ្ហាទាក់ទងនឹងអភិបាលកិច្ចមូលដ្ឋានក្នុងព្រះរាជាណាចក្រកម្ពុជា

- ជម្រុញសមធម៌យេនឌ័រក្នុងនយោបាយមូលដ្ឋាន ដោយធានាការចូលរួម និងភាពជាតំណាងរបស់ស្ត្រីនៅក្នុងរចនាសម្ព័ន្ធអភិបាលកិច្ចរបស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សា ថ្នាក់មូលដ្ឋាន និងផ្តល់ឱកាសដល់ស្ត្រីអាចចូលរួមយ៉ាងពេញលេញក្នុងអភិបាលកិច្ចមូលដ្ឋាន
- ពង្រឹងស្ថាប័នសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដែលជាយន្តការតំណាងឲ្យក្រុមប្រឹក្សាថ្នាក់មូលដ្ឋានទូទាំងប្រទេស តាមរយៈសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់នៅតាមរាជធានី ខេត្ត ក្នុងការរៀបចំការអភិវឌ្ឍសមត្ថភាព ផ្តល់ជំនាញ និងវិជ្ជាជីវៈដល់សមាជិក
- ជម្រុញការអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋាន និងយកចិត្តទុកដាក់ចំពោះការប្រែប្រួលអាកាសធាតុដោយមានការគាំទ្រ និងចូលរួមពីក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន។

## ជំពូកទី៤

## សមាជិកភាព

### មាត្រា ៨.- សមាសភាព

សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ រួមមានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៅតាមរាជធានី ខេត្ត ជាសមាជិក។ សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវចាប់ផ្តើមដោយមានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៅតាមរាជធានី ខេត្ត យ៉ាងតិចចំនួនមួយភាគបីនៃចំនួនរាជធានី ខេត្តទូទាំងប្រទេសចូលរួមជាសមាជិក។

ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ដែលមានបំណងក្លាយទៅជាសមាជិកភាពរបស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ត្រូវចូលជាសមាជិកសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៅតាមរាជធានី ខេត្តសាមីជាមុនសិន។

### មាត្រា ៩.- ការចូលជាសមាជិកភាព

ការចូលជាសមាជិកសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវបំពេញតាមល័ក្ខខ័ណ្ឌ ដូចខាងក្រោម ៖

- ជាសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៅតាមរាជធានី ខេត្ត

• ដាក់ពាក្យសុំចូលជាសមាជិកភាពរបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដោយស្ម័គ្រចិត្ត
• បង់ប្រាក់សមាជិកភាពប្រចាំឆ្នាំ តាមការកំណត់នៅក្នុងបទបញ្ជាផ្ទៃក្នុង
• អនុវត្តតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។

### មាត្រា ១០.- ការបាត់បង់សមាជិកភាព

សមាជិកភាពរបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នឹងត្រូវបាត់បង់តាមករណីណាមួយ ដូចខាងក្រោម ៖

• ដាក់ពាក្យសុំលាលែងដោយស្ម័គ្រចិត្ត និងដោយមានសំឡេងយល់ព្រមមិនតិចជាងពីរភាគបីនៃចំនួនសមាជិកទាំងអស់របស់គណៈកម្មាធិការប្រតិបត្តិនៃសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៅតាមរាជធានី ខេត្តសាមី
• មិនបានបង់ប្រាក់សមាជិកភាពប្រចាំឆ្នាំតាមការកំណត់ចំនួនពីរឆ្នាំបន្តបន្ទាប់ដោយគ្មានមូលហេតុ
• រំលោភបំពានលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន។

### មាត្រា ១១.- ការចូលជាសមាជិកភាពសារជាថ្មី

ការចូលជាសមាជិករបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ សារជាថ្មី ត្រូវបំពេញតាមល័ក្ខខ័ណ្ឌដូចខាងក្រោម ៖

• ស្ម័គ្រចិត្តដាក់ពាក្យសុំចូលជាសមាជិកសារជាថ្មី
• ស្ម័គ្រចិត្តបង់ប្រាក់សមាជិកភាពប្រចាំឆ្នាំដែលខ្លួនមិនបានបង់គ្រប់ចំនួនឡើងវិញ
• សន្យាជាលាយល័ក្ខណ៍អក្សរថានឹងកែលំអកំហុសឆ្គងរបស់ខ្លួនកន្លងមក។

## ជំពូកទី៥

## រចនាសម្ព័ន្ធ និងតួនាទី

### មាត្រា ១២.-រចនាសម្ព័ន្ធ

សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់មានរចនាសម្ព័ន្ធដូចខាងក្រោម៖

• មហាសន្និបាត
• ក្រុមប្រឹក្សាជាតិ

• គណៈកម្មាធិការប្រតិបត្តិជាតិ
• ថ្នាក់ដឹកនាំ
• អគ្គលេខាធិការដ្ឋាន។

## មហាសន្និបាត

### មាត្រា ១៣.-ប្រតិភូមហាសន្និបាត

មហាសន្និបាត មានប្រតិភូចូលរួមដូចតទៅៈ

• ប្រធាន និងអនុប្រធានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៅតាមរាជធានី ខេត្ត
• ប្រតិភូមកពីក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដែលជាសមាជិករបស់សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៅតាមរាជធានី ខេត្ត។

ប្រតិភូគឺជាសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងជាតំណាងផ្លូវការរបស់សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៅតាមរាជធានី ខេត្ត។

ប្រតិភូមហាសន្និបាតតំណាងឲ្យក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ នៅទូទាំងប្រទេស។

ប្រតិភូគ្រប់រូប អាចបោះឆ្នោតមួយសំឡេងលើរាល់កិច្ចការដែលតម្រូវឱ្យមានសេចក្ដីសម្រេចចិត្តរបស់មហាសន្និបាត។

ក្រៅពីមានសិទ្ធិបោះឆ្នោតក្នុងឋានៈជាប្រតិភូ សំឡេងរបស់ប្រធានមហាសន្និបាតមានឧត្តមានុភាព ក្នុងករណីដែលមានសំឡេងឆ្នោតស្មើគ្នាលើកិច្ចការដែលតម្រូវឱ្យមានសេចក្តីសម្រេចចិត្តរបស់មហាសន្និបាត។

### មាត្រា ១៤.- ប្រធាន អនុប្រធានមហាសន្និបាត

មហាសន្និបាតត្រូវអនុម័តជ្រើសរើសប្រធានមួយរូប និងអនុប្រធានមួយចំនួន ពីក្នុងចំណោមប្រតិភូចូលរួមនៅក្នុងមហាសន្និបាត។

ប្រធាន និងអនុប្រធានដែលត្រូវបានអនុម័តជ្រើសរើសដោយសំឡេងហាសិបភាគរយបូកមួយពីប្រតិភូចូលរួមនៅក្នុងមហាសន្និបាត គឺជាប្រធាន និងអនុប្រធានមហាសន្និបាត។

អគ្គលេខាធិការសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ គឺជាអគ្គលេខាធិការមហាសន្និបាត។

## មាត្រា ១៥.- ការរៀបចំមហាសន្និបាត

មហាសន្និបាត ត្រូវរៀបចំឡើងក្នុងរយៈពេលប្រាំឆ្នាំម្តងនៅព្រះរាជាណាចក្រកម្ពុជា។

ក្រៅពីមហាសន្និបាតប្រាំឆ្នាំម្តង សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ អាចធ្វើមហាសន្និបាតវិសាមញ្ញ នៅពេលណាមួយនៅព្រះរាជាណាចក្រកម្ពុជា ដើម្បីពិចារណាការងារដែលជាផលប្រយោជន៍របស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងដើម្បីពិនិត្យ និងដោះស្រាយបញ្ហានៅមុនមហាសន្និបាតនាពេលបន្ទាប់។

ប្រធានសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវកោះប្រជុំមហាសន្និបាតនៅរៀងរាល់ប្រាំឆ្នាំម្តង។

ក្នុងករណីប្រធានសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មិនមានការកោះប្រជុំ ដោយគ្មានបញ្ជាក់ពីហេតុផលក្នុងរយៈពេលពីរខែបន្ទាប់ពីបានបញ្ចប់អាណត្តិរយៈពេល ៥ ឆ្នាំ អគ្គលេខាធិការមានសិទ្ធិជាស្វ័យប្រវត្តិក្នុងការចាត់ចែងរៀបចំ និងអញ្ជើញក្រុមប្រឹក្សាថ្នាក់មូលដ្ឋានចូលរួមក្នុងមហាសន្និបាត។

សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវកោះប្រជុំមហាសន្និបាតវិសាមញ្ញ នៅពេលមានសំណើជាលាយល័ក្ខណ៍អក្សរ ដោយមានបញ្ជាក់ប្រធានបទ និងមូលហេតុពីសំណាក់ ៖

- ក្រុមប្រឹក្សាថ្នាក់មូលដ្ឋានដែលជាសមាជិករបស់សម្ព័ន្ធភាពជាតិ មិនតិចជាង ៣៣ ភាគរយ ឬ
- សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៅតាមរាជធានី ខេត្ត មិនតិចជាង ៣៣ ភាគរយ ឬ
- សមាជិកក្រុមប្រឹក្សាជាតិ មិនតិចជាង ៥០ ភាគរយ ឬ
- សមាជិកគណៈកម្មាធិការប្រតិបត្តិជាតិទាំងអស់។

## មាត្រា ១៦.- ភារកិច្ចរបស់មហាសន្និបាត

មហាសន្និបាត មានភារកិច្ច៖

- សម្រេចលើចំនួនថ្នាក់ដឹកនាំរបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- បោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានអចិន្ត្រៃយ៍ និងអនុប្រធានមួយចំនួនរបស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន

- បោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាជាតិ
- អនុម័ត បទបញ្ជា និងនីតិវិធីបំពេញការងាររបស់មហាសន្និបាត
- អនុម័ត ត្រា និងរូបសញ្ញាជាផ្លូវការរបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- ធ្វើវិសោធនកម្មលក្ខន្តិកៈសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- អនុម័តល័ក្ខខ័ណ្ឌសម្រាប់សមាជិករបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- ពិនិត្យ វាយតម្លៃសមិទ្ធផលសម្រេចបានធៀបនឹងគោលបំណង និងទិសដៅរបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- ពិនិត្យ និងអនុម័តនីតិវិធីបំពេញការងារ ការកោះប្រជុំ ការប្រព្រឹត្តិទៅនៃអង្គប្រជុំ និងការធ្វើប្រតិភូកម្មការទទួលខុសត្រូវដល់ផ្នែកនានាដែលស្ថិតនៅក្នុងរចនា-សម្ព័ន្ធរបស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន
- អនុម័តនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើស និងការបញ្ឈប់សមាជិកក្រុមប្រឹក្សាជាតិ និងគណៈកម្មាធិការប្រតិបត្តិជាតិនៃសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន
- ចាត់ចែងកិច្ចការរបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ អនុលោមតាម គោលបំណង និងទិសដៅរបស់សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៅតាមរាជធានី ខេត្ត និងសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដូចមានចែងនៅក្នុងលក្ខន្តិកៈនេះ
- ពិនិត្យមើលឡើងវិញនូវគោលនយោបាយយុទ្ធសាស្ត្រ តួនាទីរបស់ក្រុមប្រឹក្សាជាតិ គណៈកម្មាធិការប្រតិបត្តិជាតិ និងអគ្គលេខាធិការ និងសម្រេចលើកិច្ចការដែលស្ថិតនៅក្នុងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាជាតិ និងគណៈកម្មាធិការប្រតិបត្តិជាតិ ឬអគ្គលេខាធិការ
- អនុម័តការងារហិរញ្ញវត្ថុរបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងផ្នែកនានារបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- អនុម័តការងារផ្សេងទៀតដែលមានលក្ខណៈសមស្រប ឬជាការចាំបាច់ ដោយផ្អែកតាមលក្ខន្តិកៈសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- ប្រតិភូកម្មភារកិច្ចឲ្យក្រុមប្រឹក្សាជាតិ
- សម្រេចលើការរំសាយ និងការបែងចែកទ្រព្យសម្បត្តិរបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ។

# ក្រុមប្រឹក្សាជាតិ

## មាត្រា ១៧.- សមាសភាព

ក្រុមប្រឹក្សាជាតិនៃសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន មានចំនួនយ៉ាងច្រើន ១០០នាក់ ក្នុងនោះប្រតិភូមកពីក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងប្រតិភូមកពីក្រុមប្រឹក្សាឃុំ សង្កាត់ ស្របតាមគោលការណ៍សមធម៌ និងស្ថានភាពជាក់ស្តែង។

សមាជិកក្រុមប្រឹក្សាជាតិត្រូវបោះឆ្នោតជ្រើសរើសឡើងដោយ និងពីក្នុងចំណោមប្រតិភូចូលរួមនៅក្នុងមហាសន្និបាត។

ប្រធាន អនុប្រធានសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន គឺជាប្រធាន អនុ-ប្រធានក្រុមប្រឹក្សាជាតិ។

## មាត្រា ១៨.- អាណត្តិរបស់ក្រុមប្រឹក្សាជាតិ

ប្រធាន អនុប្រធាន និងសមាជិកក្រុមប្រឹក្សាជាតិ មានអាណត្តិប្រាំឆ្នាំ។ ប្រធាន អនុប្រធាន និងសមាជិកក្រុមប្រឹក្សាជាតិដែលបាត់បង់តំណែងជាសមាជិកក្រុមប្រឹក្សាថ្នាក់មូលដ្ឋានរបស់ខ្លួន ត្រូវបាត់បង់លក្ខណៈសម្បត្តិជាប្រធាន អនុប្រធាន និងសមាជិកក្រុមប្រឹក្សាជាតិដោយស្វ័យប្រវត្តិ។

ប្រធាន អនុប្រធាន និងសមាជិកក្រុមប្រឹក្សាជាតិដែលបានបាត់បង់ ត្រូវបំពេញជំនួសវិញដោយតំណាងមកពីក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់នៃរាជធានី ខេត្ត ដែលសមាជិកនោះបានបាត់បង់ ឬសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៅតាមរាជធានី ខេត្ត ជាអ្នកស្នើតែងតាំងជំនួស។

## មាត្រា ១៩.- កិច្ចប្រជុំរបស់ក្រុមប្រឹក្សាជាតិ

ក្រុមប្រឹក្សាជាតិ ត្រូវប្រជុំម្តងក្នុងរយៈពេលមួយឆ្នាំនៅព្រះរាជាណាចក្រកម្ពុជា។

ក្រៅពីការប្រជុំមួយឆ្នាំម្តង ក្រុមប្រឹក្សាជាតិអាចប្រជុំវិសាមញ្ញនៅពេលណាមួយនៅព្រះរាជាណាចក្រកម្ពុជា ដើម្បីពិចារណាការងារដែលជាផលប្រយោជន៍របស់ក្រុមប្រឹក្សាជាតិ ដើម្បីពិនិត្យ និងដោះស្រាយនៅមុនពេលប្រជុំប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាជាតិនាពេលបន្ទាប់។

ប្រធានក្រុមប្រឹក្សាជាតិត្រូវកោះប្រជុំប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាជាតិ។

ប្រធានក្រុមប្រឹក្សាជាតិ ត្រូវកោះប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាជាតិ នៅពេលមានសំណើជាលាយល័ក្ខណ៍អក្សរដោយមានបញ្ជាក់ប្រធានបទ និងមូលហេតុពីសំណាក់៖

- ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ជាសមាជិករបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មិនតិចជាង ៣៣ ភាគរយ ឬ
- សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៅតាមរាជធានី ខេត្ត មិនតិចជាង ៣៣ ភាគរយ ឬ
- សមាជិកក្រុមប្រឹក្សាជាតិមិនតិចជាង ៥០ ភាគរយ ឬ
- សមាជិកគណៈកម្មាធិការប្រតិបត្តិជាតិទាំងអស់។

កិច្ចប្រជុំក្រុមប្រឹក្សាជាតិ អាចដំណើការបាន នៅពេលមានការចូលរួមពីសំណាក់សមាជិកក្រុមប្រឹក្សាជាតិមិនតិចជាងពាក់កណ្ដាលនៃចំនួនសមាជិកទាំងអស់ហើយ សេចក្ដីសម្រេចមានសុពលភាពដរាបណាមានការគាំទ្រតាមសំឡេងហាសិបភាគរយបូកមួយនៃអ្នកចូលរួមប្រជុំ។

## មាត្រា ២០.- ភារកិច្ចរបស់ក្រុមប្រឹក្សាជាតិ

ក្រុមប្រឹក្សាជាតិ មានភារកិច្ចៈ

- បោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មាធិការប្រតិបត្តិជាតិ
- អនុម័តក្រុមសវនករផ្ទៃក្នុងរបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ យ៉ាងច្រើន ០៧ រូប
- គ្រប់គ្រង និងដឹកនាំការងាររបស់សម្ព័ន្ធភាពជាតិសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នៅចន្លោះពេលមហាសន្និបាតដែលរៀបចំឡើងក្នុងរយៈពេល ៥ ឆ្នាំម្ដង អនុលោមទៅតាមគោលបំណង និងទិសដៅរបស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន និងសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៅតាមរាជធានី ខេត្ត ដូចមានចែងក្នុងលក្ខន្តិកៈនេះ
- ពិនិត្យ និងអនុម័តក្របខ័ណ្ឌយុទ្ធសាស្ត្ររបស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន
- ពិនិត្យ និងអនុម័តគោលនយោបាយរដ្ឋបាល និងហិរញ្ញវត្ថុរបស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន
- ពិនិត្យ និងកែសម្រួលលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- រៀបចំ និងអនុម័តសេចក្ដីជូនដំណឹង ជំនួយស្មារតី ដែលអាចតម្រូវឱ្យមាននៅចន្លោះពេលមហាសន្និបាត
- ផ្ដួចផ្ដើម និងសម្រេចលើកិច្ចការដែលស្របនឹងគោលបំណង និងទិសដៅទាំងនេះ
- ពិនិត្យ និងអនុម័តផែនការសកម្មភាព កម្មវិធី និងថវិកាប្រចាំឆ្នាំរបស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន

- ពិនិត្យ និងអនុម័តរបាយការណ៍សកម្មភាព និងហិរញ្ញវត្ថុរបស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន
- ពិនិត្យមើលលើកិច្ចការហិរញ្ញវត្ថុរបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- វាយការណ៍ ផ្តល់អនុសាសន៍ សេចក្តីសម្រេច និងសកម្មភាពរបស់ខ្លួនជាលាយ-ល័ក្ខណ៍អក្សរ និងដាក់របាយការណ៍សវនកម្មប្រចាំឆ្នាំជូនមហាសន្និបាតនាពេលបន្ទាប់
- ពិនិត្យ និងស្តាប់របាយការណ៍ប្រចាំឆ្នាំនៃសវនកម្មខាងក្នុង និងខាងក្រៅរបស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន
- វាយតម្លៃប្រសិទ្ធភាពគ្រប់គ្រងរបស់ប្រធាន អនុប្រធានសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- អនុម័តសមាជិកភាពសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- ប្រតិភូកម្មសិទ្ធិអំណាចដល់គណៈកម្មាធិការប្រតិបត្តិជាតិ។

សមាជិកគ្រប់រូបរបស់ក្រុមប្រឹក្សាជាតិ មានសិទ្ធិបោះឆ្នោតមួយសំឡេងលើកិច្ចការដែលតម្រូវឱ្យមានសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជាតិ។

## មាត្រា ២១.- ភារកិច្ចរបស់ប្រធានក្រុមប្រឹក្សាជាតិ

ប្រធានក្រុមប្រឹក្សាជាតិមានភារកិច្ច ៖

- រៀបចំកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាជាតិ
- ធ្វើជាអធិបតីក្នុងកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាជាតិ
- អនុវត្តភារកិច្ចផ្សេងៗ ដែលតម្រូវដោយលក្ខន្តិកៈនេះ ឬដោយបទបញ្ជាផ្ទៃក្នុង
- ប្រកាន់យកការទទួលខុសត្រូវផ្សេងទៀត ដែលតម្រូវដោយសេចក្តីសម្រេចរបស់មហាសន្និបាត ឬក្រុមប្រឹក្សាជាតិ។

ក្រៅពីមានសិទ្ធិបោះឆ្នោតក្នុងឋានៈជាប្រតិភូ សំឡេងរបស់ប្រធានក្រុមប្រឹក្សាជាតិមានឧត្តមានុភាព ក្នុងករណីមានសំឡេងឆ្នោតស្មើគ្នាលើកិច្ចការដែលតម្រូវឱ្យមានសេចក្តីសម្រេចពីក្រុមប្រឹក្សាជាតិ។

អនុប្រធានអចិន្ត្រៃយ៍ ឬអនុប្រធានណាម្នាក់ដែលជាប្រធានស្តីទីរបស់ក្រុមប្រឹក្សាជាតិ មានភារកិច្ចចាត់ចែងរាល់កិច្ចការរបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នៅពេលប្រធានអវត្តមាន។

## គណៈកម្មាធិការប្រតិបត្តិជាតិ

### មាត្រា ២២.- សមាសភាព

គណៈកម្មាធិការប្រតិបត្តិជាតិនៃសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មានសមាសភាពមិនតិចជាងមួយភាគបីនៃសមាសភាពក្រុមប្រឹក្សាជាតិ ក្នុងនោះប្រតិភូមកពីក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងប្រតិភូមកពីក្រុមប្រឹក្សាឃុំ សង្កាត់ ស្របតាមគោលការណ៍សមធម៌ និងស្ថានភាពជាក់ស្តែង។

គណៈកម្មាធិការប្រតិបត្តិជាតិ មានសមាជិកដែលត្រូវបោះឆ្នោតជ្រើសរើសដោយ និងពីក្នុងចំណោមប្រតិភូនៅក្នុងក្រុមប្រឹក្សាជាតិ។

ប្រធាន និងអនុប្រធានក្រុមប្រឹក្សាជាតិ គឺជាប្រធាន និងអនុប្រធានគណៈកម្មាធិការប្រតិបត្តិជាតិ ។

### មាត្រា ២៣.- អាណត្តិរបស់គណៈកម្មាធិការប្រតិបត្តិជាតិ

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការប្រតិបត្តិជាតិ មានអាណត្តិប្រាំឆ្នាំ។ ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការប្រតិបត្តិជាតិដែលបាត់បង់តំណែងជាសមាជិកក្រុមប្រឹក្សាថ្នាក់មូលដ្ឋានរបស់ខ្លួន ត្រូវបាត់បង់លក្ខណៈសម្បត្តិជាប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការប្រតិបត្តិជាតិដោយស្វ័យប្រវត្តិ។

ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការប្រតិបត្តិជាតិដែលបានបាត់បង់តំណែង ត្រូវបំពេញជំនួសវិញដោយតំណាងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់នៃរាជធានី ឬខេត្ត ដែលសមាជិកនោះបានបាត់បង់ ឬសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៅតាមរាជធានី ខេត្ត ជាអ្នកស្នើតែងតាំងជំនួស។

### មាត្រា ២៤.- កិច្ចប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិជាតិ

គណៈកម្មាធិការប្រតិបត្តិជាតិ ត្រូវប្រជុំម្តងក្នុងរយៈពេលប្រាំមួយខែ នៅព្រះរាជាណាចក្រកម្ពុជា។ ក្រៅពីការប្រជុំប្រាំមួយខែម្តង គណៈកម្មាធិការប្រតិបត្តិជាតិអាចប្រជុំវិសាមញ្ញនៅព្រះរាជាណាចក្រកម្ពុជា ដើម្បីពិចារណាការងារ ដែលជាផលប្រយោជន៍របស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងដើម្បីពិនិត្យ និងដោះស្រាយការងារនៅមុនការប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិជាតិនាពេលបន្ទាប់។

ប្រធានគណៈកម្មាធិការប្រតិបត្តិជាតិ ត្រូវកោះប្រជុំគណៈកម្មាធិការប្រតិបត្តិជាតិរៀងរាល់ប្រាំមួយខែម្តង។

ប្រធានគណៈកម្មាធិការប្រតិបត្តិជាតិ ត្រូវកោះប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការប្រតិបត្តិជាតិនៅពេលមានសំណើជាលាយល័ក្ខណ៍អក្សរ ពីសមាជិកនៅក្នុងគណៈកម្មាធិការប្រតិបត្តិជាតិ មិនតិចជាងពីរភាគបី ដោយមានបញ្ជាក់ប្រធានបទ និងមូលហេតុ។

កិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិជាតិ អាចដំណើការបាន នៅពេលមានការចូលរួមពីសំណាក់សមាជិកគណៈកម្មាធិការប្រតិបត្តិជាតិមិនតិចជាងពាក់កណ្តាលនៃចំនួនសមាជិកទាំងអស់ ហើយសេចក្តីសម្រេចមានសុពលភាពដរាបណាមានការគាំទ្រតាមសំឡេងហាសិបភាគរយបូកមួយនៃអ្នកចូលរួមប្រជុំ។

**មាត្រា ២៥.- ភារកិច្ចរបស់គណៈកម្មាធិការប្រតិបត្តិជាតិ**

គណៈកម្មាធិការប្រតិបត្តិជាតិ មានភារកិច្ច ៖

- គ្រប់គ្រង និងពិនិត្យមើលការងាររបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នៅចន្លោះពេលប្រជុំប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាជាតិ អនុលោមទៅតាមគោលបំណង និងទិសដៅរបស់សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៅតាមរាជធានី ខេត្ត និងសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដូចមានចែងនៅក្នុងលក្ខន្តិកៈនេះ
- ផ្តួចផ្តើម និងផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាជាតិចំពោះការងារដែលស្របនឹងគោលបំណង និងទិសដៅទាំងនេះ
- សម្រេច និងអនុវត្តការងារដែលស្របនឹងគោលបំណង និងទិសដៅ និងស្ថិតនៅក្នុងសិទ្ធិអំណាចរបស់គណៈកម្មាធិការប្រតិបត្តិជាតិ
- ផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាជាតិអំពីថវិកាប្រចាំឆ្នាំរបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- ត្រួតពិនិត្យកិច្ចការហិរញ្ញវត្ថុរបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- សម្រេចលើការជ្រើសរើស ការតែងតាំង ការបញ្ឈប់ អគ្គលេខាធិការ និងអគ្គលេខាធិការរងស្របតាមគោលនយោបាយគ្រប់គ្រងបុគ្គលិក
- សម្រេចលើការតែងតាំងគណៈកម្មការនានារបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- កំណត់ល័ក្ខខ័ណ្ឌការងារ និងការទទួលខុសត្រូវរបស់អគ្គលេខាធិការ និងអគ្គលេខាធិការរង
- វាយតម្លៃប្រសិទ្ធភាពគ្រប់គ្រង និងការអនុវត្តការងាររបស់អគ្គលេខាធិការ និងអគ្គលេខាធិការរងរបស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន

- ផ្ដល់អនុសាសន៍ សេចក្ដីសម្រេច និងរាយការណ៍សកម្មភាពរបស់ខ្លួនជាលាយ-លក្ខណ៍អក្សរ និងដាក់របាយការណ៍សវនកម្មប្រចាំឆ្នាំជូនកិច្ចប្រជុំរបស់ក្រុមប្រឹក្សាជាតិនាពេលបន្ទាប់
- ត្រួតពិនិត្យក្របខ័ណ្ឌយុទ្ធសាស្ត្ររបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងផ្ដល់ជាគោលការណ៍ណែនាំក្នុងការតម្រង់ទិសសំដៅអភិវឌ្ឍសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- ពិនិត្យ និងអនុម័តផែនការសកម្មភាព និងថវិកាប្រចាំឆមាស
- ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការងារ ការរីកចម្រើន បញ្ហាប្រឈម និងដំណោះស្រាយនៅរៀងរាល់ឆមាស
- ផ្ដល់យោបល់ និងអនុសាសន៍ដល់ក្រុមប្រឹក្សាជាតិ
- ពិនិត្យមើលគោលនយោបាយបុគ្គលិក និងគោលនយោបាយគ្រប់គ្រងទីប្រឹក្សា
- ប្រតិភូកម្មសិទ្ធិអំណាចដល់ប្រធាន និងអនុប្រធានសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន។

**មាត្រា ២៦.- ភារកិច្ចរបស់ប្រធានគណៈកម្មាធិការប្រតិបត្តិជាតិ**

ប្រធានគណៈកម្មាធិការប្រតិបត្តិជាតិ មានភារកិច្ច ៖

- រៀបចំកិច្ចប្រជុំទាំងអស់របស់គណៈកម្មាធិការប្រតិបត្តិជាតិ
- ធ្វើជាអធិបតីក្នុងកិច្ចប្រជុំទាំងអស់របស់គណៈកម្មាធិការប្រតិបត្តិជាតិ
- អនុវត្តភារកិច្ចផ្សេងៗ ដែលតម្រូវដោយលក្ខន្តិកៈនេះ ឬដោយបទបញ្ជាផ្ទៃក្នុង
- ប្រកាន់យកការទទួលខុសត្រូវផ្សេងទៀត ដែលតម្រូវដោយសេចក្ដីសម្រេចរបស់គណៈ កម្មាធិការប្រតិបត្តិជាតិ ឬក្រុមប្រឹក្សាជាតិ។

នៅពេលប្រធានអវត្តមាន អនុប្រធានអចិន្ត្រៃយ៍ ឬអនុប្រធានណាម្នាក់ដែលជាប្រធានស្ដីទី ត្រូវចាត់ចែងរាល់ការងាររបស់គណៈកម្មាធិការប្រតិបត្តិជាតិ។

**មាត្រា ២៧.- គណៈកម្មការរបស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន**

គណៈកម្មាធិការប្រតិបត្តិជាតិ អាចតែងតាំងគណៈកម្មការពីក្នុងចំណោមសមាជិករបស់ខ្លួន ឬពីក្នុងចំណោមបុគ្គលផ្សេងទៀត ដើម្បីផ្ដល់យោបល់ និងជួយការងាររបស់គណៈកម្មាធិការប្រតិបត្តិជាតិ។

គណៈកម្មាធិការប្រតិបត្តិជាតិ ត្រូវសម្រេចលើលក្ខខ័ណ្ឌការងារ និងតួនាទី ភារកិច្ចរបស់គណៈកម្មការនីមួយៗ។

## ថ្នាក់ដឹកនាំ

### មាត្រា ២៨.- សមាសភាព

ថ្នាក់ដឹកនាំដែលជាប្រធាន អនុប្រធានសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ អាចមានចំនួនពី ៧ ទៅ ១១ នាក់ អាស្រ័យលើការសម្រេចរបស់មហាសន្និបាត។

ថ្នាក់ដឹកនាំសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវបោះឆ្នោតជ្រើសរើសឡើងដោយ និងពីក្នុងចំណោមប្រតិភូចូលរួមនៅក្នុងមហាសន្និបាត។

### មាត្រា ២៩.- អាណត្តិរបស់ថ្នាក់ដឹកនាំ

ថ្នាក់ដឹកនាំសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មានអាណត្តិប្រាំឆ្នាំ។ ថ្នាក់ដឹកនាំដែលបាត់បង់តំណែងជាសមាជិកក្រុមប្រឹក្សាថ្នាក់មូលដ្ឋានរបស់ខ្លួន ត្រូវបាត់បង់លក្ខណៈសម្បត្តិជាថ្នាក់ដឹកនាំសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ដោយស្វ័យប្រវត្តិ។

ក្នុងករណីបាត់បង់សមាជិកភាពប្រធានសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ថ្នាក់ដឹកនាំសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវបើកកិច្ចប្រជុំ ដើម្បីពិនិត្យ ពិភាក្សា និងសម្រេចជ្រើសរើសអនុប្រធានណាម្នាក់ឲ្យទទួលជាប្រធានស្តីទី។

គណៈកម្មាធិការប្រតិបត្តិជាតិ ត្រូវបោះឆ្នោតបំពេញបន្ថែមប្រធាន និងអនុប្រធានពេញសិទ្ធិ។

ក្នុងករណីបាត់បង់សមាជិកភាពអនុប្រធានសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ គណៈកម្មាធិការប្រតិបត្តិជាតិ ត្រូវបើកកិច្ចប្រជុំ ដើម្បីពិនិត្យ ពិភាក្សា និងសម្រេចជ្រើសរើសសមាជិកពីក្នុងគណៈកម្មាធិការប្រតិបត្តិជាតិឲ្យទទួលជាអនុប្រធានសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន។

### មាត្រា ៣០.- កិច្ចប្រជុំរបស់ថ្នាក់ដឹកនាំ

ថ្នាក់ដឹកនាំសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវជួបប្រជុំយ៉ាងតិចម្តងក្នុង មួយខែ។

សេចក្តីសម្រេចរបស់ថ្នាក់ដឹកនាំ អាចមានសុពលភាពបានលុះត្រាតែមានការគាំទ្រដោយសំឡេងឆ្នោតហាសិបភាគរយបូកមួយ (៥០%+១) លើកូរ៉ុមដែលចូលរួមនៅក្នុងកិច្ចប្រជុំ។ ក្នុងករណីដែលសំឡេងឆ្នោតស្មើគ្នា សំឡេងរបស់ប្រធានមានឧត្តមានុភាព។

អគ្គលេខាធិការដ្ឋានសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ត្រូវរ៉ាប់រងទទួលរៀបចំ កិច្ចប្រជុំរបស់ថ្នាក់ដឹកនាំសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន។

### មាត្រា ៣១.- ភារកិច្ចរបស់ថ្នាក់ដឹកនាំ

ថ្នាក់ដឹកនាំ មានភារកិច្ចៈ

- បំពេញភារកិច្ចតាមការផ្ទេរប្រតិភូកម្មដោយក្រុមប្រឹក្សាជាតិ និងគណៈកម្មាធិការប្រតិបត្តិជាតិ
- តំណាងឲ្យសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់នៅក្នុងការជួបប្រាស្រ័យទាក់ទងជាមួយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ ភ្ញៀវជាតិ និងអន្តរជាតិ
- រៀបចំ និងផ្តល់ប័ណ្ណសំគាល់ខ្លួនជូនដល់សមាជិកក្រុមប្រឹក្សាជាតិ និងគណៈកម្មាធិការប្រតិបត្តិជាតិ
- ផ្តល់យោបល់ដឹកនាំអំពីការបំពេញការងារនៅអគ្គលេខាធិការដ្ឋាន
- ពិនិត្យមើលការបំពេញការងារប្រចាំថ្ងៃរបស់អគ្គលេខាធិការ និងអគ្គលេខាធិការរង
- ធានាឲ្យអគ្គលេខាធិការ អគ្គលេខាធិការរង និងបុគ្គលិកនៅអគ្គលេខាធិការដ្ឋានបំពេញការងារស្របទៅតាមគោលនយោបាយរដ្ឋបាល និងហិរញ្ញវត្ថុ។

## អគ្គលេខាធិការដ្ឋានសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន

### មាត្រា ៣២.- អគ្គលេខាធិការដ្ឋាន

សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មានអគ្គលេខាធិការដ្ឋានរបស់ខ្លួន ដើម្បីគ្រប់គ្រងការងារប្រចាំថ្ងៃរបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងផ្នែកនានារបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និង ដើម្បីជួយរៀបចំចាត់ចែងមហាសន្និបាត កិច្ចប្រជុំក្រុមប្រឹក្សាជាតិ និងកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិជាតិទៅតាមការចាំបាច់។

អគ្គលេខាធិការ អាចចូលរួម និងមានមតិនៅក្នុងអង្គប្រជុំទាំងអស់ ប៉ុន្តែមិនមានសិទ្ធិបោះឆ្នោតទេ។

អគ្គលេខាធិការ ត្រូវជ្រើសរើសដោយគណៈកម្មាធិការប្រតិបត្តិជាតិនៃសម្ព័ន្ធភាពក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ។

### មាត្រា ៣៣.- លក្ខណៈសម្បត្តិអគ្គលេខាធិការ

អគ្គលេខាធិការ ត្រូវមានលក្ខណៈសម្បត្តិ ដូចខាងក្រោមៈ

- មានអាយុយ៉ាងតិច ២៥ឆ្នាំ
- កំរិតវប្បធម៌ ទាបបំផុត កម្រិតបរិញ្ញាបត្រ
- មានបទពិសោធន៍យ៉ាងតិច ០៧ ឆ្នាំ លើការងារអភិបាលកិច្ច ការតាក់តែងគោល-នយោបាយ ផែនការយុទ្ធសាស្ត្រ ទំនាក់ទំនងនិងការស្វែងរកការគាំទ្រ ការគ្រប់គ្រងកម្មវិធី ការអភិវឌ្ឍសមត្ថភាព និងការអភិវឌ្ឍស្ថាប័ន។
- មានអាកប្បកិរិយា និងសីលធម៌ល្អ
- មានលិខិតបញ្ជាក់កិរិយាមាយាទ
- មានលិខិតថ្កោលទោស
- មានសុខភាពល្អ
- មានឆន្ទៈក្នុងការបំពេញការងារ។

អគ្គលេខាធិការត្រូវបំរើការងារពេញម៉ោង។ អគ្គលេខាធិការ មិនអាចបម្រើការងារពេញម៉ោងនៅកន្លែងផ្សេងទៀតបានឡើយ។

## មាត្រា ៣៩.- ភារកិច្ចរបស់អគ្គលេខាធិការ

អគ្គលេខាធិការ មានភារកិច្ច ៖

- គ្រប់គ្រងការងារប្រចាំថ្ងៃរបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- គ្រប់គ្រង និងត្រួតពិនិត្យកិច្ចការហិរញ្ញវត្ថុរបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- ធ្វើរបាយការណ៍អំពីលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ប្រចាំឆ្នាំ និងរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងដាក់ជូនក្រុមប្រឹក្សាជាតិនៃសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- ផ្តល់អនុសាសន៍ដល់ប្រធាន អនុប្រធានសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ក្នុងការជ្រើសរើសបុគ្គលិកបំរើការងារនៅអគ្គលេខា-ធិការដ្ឋាន
- គ្រប់គ្រង តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការប្រចាំឆ្នាំ និងសេចក្តីសម្រេចទាំងឡាយរបស់គណៈកម្មាធិការប្រតិបត្តិប្រកបដោយប្រសិទ្ធភាពខ្ពស់
- រាយការណ៍ពីបញ្ហាប្រឈម និងលើកយោបល់ជូនមហាសន្និបាត ក្រុមប្រឹក្សាជាតិ គណៈកម្មាធិការប្រតិបត្តិជាតិ គណៈកម្មការនានា និងប្រធាន អនុប្រធានសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់

- គ្រប់គ្រងបុគ្គលិក និងនិយោជិកទាំងអស់ រួមទាំងអគ្គលេខាធិការរងសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- ស្នើយោបល់ទៅគណៈកម្មាធិការប្រតិបត្តិជាតិក្នុងការតែងតាំងអគ្គលេខាធិការរង
- អនុវត្តភារកិច្ចផ្សេងៗ ដែលតម្រូវដោយលក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុងរបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- ប្រកាន់យកការទទួលខុសត្រូវផ្សេងទៀត តាមការប្រគល់ភារកិច្ចពីប្រធាន អនុប្រធានសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- រក្សាការទំនាក់ទំនងល្អជាមួយក្រសួង ស្ថាប័ន អង្គការជាតិ និងអន្តរជាតិ អ្នកផ្តល់ជំនួយ និងដៃគូដទៃទៀត។

## មាត្រា ៣៥.- អគ្គលេខាធិការរង

អគ្គលេខាធិការរង ត្រូវមានល័ក្ខខ័ណ្ឌការងារសម្រាប់បំពេញតួនាទី និងភារកិច្ចរបស់ខ្លួន។ អគ្គលេខាធិការរងណាម្នាក់ នឹងក្លាយជាអគ្គលេខាធិការស្តីទីក្នុងអំឡុងពេលអវត្តមាន ឬការលាឈប់របស់អគ្គលេខាធិការ។ អគ្គលេខាធិការរងត្រូវបំរើការងារពេញម៉ោង។ អគ្គលេខាធិការរង មិនអាចបម្រើការងារពេញម៉ោងនៅកន្លែងផ្សេងទៀតបានឡើយ។

## មាត្រា ៣៦.- ក្រុមទីប្រឹក្សាគោលនយោបាយ

សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន អាចបង្កើតក្រុមទីប្រឹក្សាគោលនយោបាយ។

ការរៀបចំ ការប្រព្រឹត្តិទៅ និងការរំសាយក្រុមទីប្រឹក្សាគោលនយោបាយ នឹងត្រូវកំណត់ដោយសេចក្តីណែនាំដោយឡែកដែលនឹងត្រូវអនុម័តដោយក្រុមប្រឹក្សាជាតិ។

# ជំពូកទី៦

# ប្រាក់ចំណូល ចំណាយ និងកិច្ចការហិរញ្ញវត្ថុ

## មាត្រា ៣៧.- ប្រាក់សមាជិកភាពប្រចាំឆ្នាំ

មហាសន្និបាតអាចធ្វើប្រតិភូកម្មអំណាចឱ្យក្រុមប្រឹក្សាជាតិ កំណត់ និងពិនិត្យមើលចំនួនទឹកប្រាក់សមាជិកភាពប្រចាំឆ្នាំ ដែលសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៅតាមរាជធានី ខេត្ត ត្រូវប្រមូល។

សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ អាចទទួលប្រាក់ពីសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៅតាមរាជធានី ខេត្ត នីមួយៗ តាមការចែករំលែកប្រាក់សមាជិកភាពប្រចាំឆ្នាំ ដែលសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៅតាមរាជធានី ខេត្ត បានប្រមូល។

សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៅតាមរាជធានី ខេត្ត ត្រូវផ្ទេរថវិកាចំនួន ២០% នៃប្រាក់សមាជិកភាពប្រមូលបានក្នុងរាជធានី ខេត្ត មកសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ទៅតាមឆ្នាំសារពើពន្ធ។

## មាត្រា ៣៨.- ប្រភពចំណូលផ្សេងៗ

ក្រៅពីប្រាក់សមាជិកភាពប្រចាំឆ្នាំ សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ អាចទទួលចំណូល និងធនធានដទៃទៀតដែលបានមកពី ៖

- អតិរេក ឬប្រាក់សន្សំពីកម្មវិធី និងសកម្មភាពផ្សេងទៀតរបស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន
- វិភាជន៍ពីរាជរដ្ឋាភិបាល
- វិភាជន៍ បរិវិសទាន ភាគទាន វិភាគទាន និងអំណោយពីប្រភពស្របច្បាប់ផ្សេងទៀត រួមមានអ្នកផ្តល់អំណោយ និងទីភ្នាក់ងារអន្តរជាតិ
- ប្រាក់ទទួលបានពីការផ្តល់ជំនួយ និងរង្វាន់
- ការផ្សាយពាណិជ្ជកម្ម
- កម្រៃទទួលបានពីសេវាផ្តល់ដោយសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- កម្រៃទទួលបានពីការអនុវត្តគម្រោងតាមការចរចារជាក់ស្តែង
- ប្រភពស្របច្បាប់ផ្សេងទៀតដែលមិនធ្វើឱ្យប៉ះពាល់ដល់ឯករាជ្យភាពរបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។

## មាត្រា ៣៩.- ការផ្ទេរចំណូល

សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវផ្តល់ និងផ្ទេរប្រាក់ចំណូល និងផលប្រយោជន៍ក្រៅពីប្រាក់សមាជិកភាពដែលទទួលបានពីសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៅតាមរាជធានី ខេត្តទៅឱ្យសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៅតាមរាជធានី ខេត្ត។ ការផ្តល់ខាងលើនេះ ត្រូវកំណត់ដោយគណៈកម្មាធិការប្រតិបត្តិជាតិ។

## មាត្រា ៤០.- ការចំណាយ

ការចំណាយរបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ លើប្រាក់សមាជិកភាពមាន ដូចខាងក្រោម:

- គាំទ្រកិច្ចប្រជុំអភិបាលកិច្ចរបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- ប្រាក់លើកទឹកចិត្តដល់ប្រធាន អនុប្រធាន សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- ផ្តល់ ឬបដិភាគប្រាក់បៀវត្សរ៍បុគ្គលិក
- សកម្មភាពជាសេវាសមាជិក
- បដិភាគក្នុងគម្រោងកម្មវិធីនានា។

## មាត្រា ៤១.- ក្រុមសវនកម្ម

ក្រុមសវនកម្ម គឺជាសវនករផ្ទៃក្នុង មានតួនាទី និងភារកិច្ចត្រួតពិនិត្យ តាមដានប្រតិបត្តិការផ្នែករដ្ឋបាល និងហិរញ្ញវត្ថុរបស់សមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នៅរាជធានី ខេត្ត និងសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។ ភាពមិនប្រក្រតីដែលរកឃើញដោយក្រុមសវនកម្ម នឹងត្រូវរាយការណ៍ជូនគណៈកម្មាធិការប្រតិបត្តិជាតិ និងក្រុមប្រឹក្សាជាតិ។

## មាត្រា ៤២.- ការធ្វើសវនកម្ម

ជារៀងរាល់ឆ្នាំ ប្រធាន និងអនុប្រធានសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវធ្វើការពិនិត្យ ពិភាក្សា និងសម្រេចតែងតាំងសវនករដើម្បីធ្វើសវនកម្ម ហើយរាយការណ៍ជូនគណៈកម្មាធិការប្រតិបត្តិជាតិ និងក្រុមប្រឹក្សាជាតិអំពីលទ្ធផលនៃការ ធ្វើសវនកម្ម នៃឆ្នាំសារពើពន្ធ។

សវនករ ត្រូវតែជាសវនករឯករាជ្យដែលបានចុះបញ្ជីដោយឯករាជ្យ ហើយមានលក្ខណៈសម្បត្តិដែលត្រូវបានទទួលស្គាល់ជាលក្ខណៈជាតិ អន្តរជាតិនៅក្នុងការធ្វើសវនកម្ម។

បន្ទាប់ពីបានបញ្ចប់ការធ្វើសវនកម្ម សវនករត្រូវដាក់របាយការណ៍សវនកម្មជូនប្រធាន និងអនុប្រធានសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ពិនិត្យ ពិភាក្សា និងអនុម័តរបាយការណ៍សវនកម្ម។ ច្បាប់ចម្លងនៃរបាយការណ៍សវនកម្មត្រូវផ្តល់ជូនជាបន្ទាន់ដល់សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៅតាមរាជធានី ខេត្ត ស្ថាប័ន និងទីភ្នាក់ងារទាំងអស់ដែលផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។

សវនកម្មផ្ទៃក្នុង និងខាងក្រៅត្រូវអនុវត្តឲ្យបានទៀងទាត់រៀងរាល់ឆ្នាំ ពិសេសលើប្រាក់សមាជិកភាព។ សវនកម្មខាងក្រៅត្រូវធ្វើឡើងតែមួយលើករួមគ្នាគ្របដណ្តប់លើគ្រប់ សកម្មភាព និងថវិការបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ទាំងប្រាក់សមាជិកភាព គម្រោងនិងប្រាក់ចំណូលដទៃទៀតរបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានតាមរាជធានី ខេត្ត។

## មាត្រា ៤៣.- ទ្រព្យសម្បត្តិនៅពេលរំសាយ

នៅពេលដែលសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវ បានប្រកាសរំសាយដោយ ស្ថាប័នមានសមត្ថកិច្ច ឬដោយមហាសន្និបាត ទ្រព្យ-សម្បត្តិ ទាំងអស់របស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ត្រូវផ្ទេរឱ្យសមាគម ក្រុមប្រឹក្សាថ្នាក់ មូលដ្ឋាននៅតាមរាជធានី ខេត្ត ឬមូលនិធិក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។

មហាសន្និបាត គឺជាអង្គអភិបាលកិច្ចខ្ពស់បំផុតក្នុងការសម្រេចរំសាយសម្ព័ន្ធភាពជាតិ ក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន។

ក្នុងករណីសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវបានរំសាយ សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៅតាមរាជធានី ខេត្ត នៅតែជានីតិបុគ្គលធ្វើសកម្មភាពក្នុងដែនសមត្ថកិច្ចរបស់ខ្លួនជាបន្ត។

## មាត្រា ៤៤.- ការរកផលកម្រៃ

សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ អាចរកផលកម្រៃ ជាមួយរូបវន្តបុគ្គល ឬជាមួយនីតិបុគ្គល ដោយស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ ការរកផលកម្រៃស្ថិតក្រោមការសម្រេចរបស់ក្រុមប្រឹក្សាជាតិ។

## មាត្រា ៤៥.- ការចុះកិច្ចព្រមព្រៀង

ដើម្បីសម្រេចបានគោលបំណងរបស់ខ្លួន សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ អាចចុះកិច្ចព្រមព្រៀងជាមួយសមាគម អង្គការ វិស័យឯកជន និង ស្ថាប័នដទៃ ក្នុង និងក្រៅប្រទេស។

សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ អាចទំនាក់ទំនង ដោយផ្ទាល់ជាមួយសមាគម អង្គការ វិស័យឯកជនជាតិ និងអន្តរជាតិ តាមការសម្រេចរបស់ ក្រុមប្រឹក្សាជាតិ។

## ជំពូកទី៧
## សមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់នៅតាមរាជធានី ខេត្ត

### មាត្រា ៤៦.- លក្ខន្តិកៈរបស់សមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់នៅតាមរាជធានី ខេត្ត

សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៅតាមរាជធានី ខេត្តដែលបានបង្កើតឡើងផ្អែកតាមលក្ខន្តិកៈនេះ ត្រូវក្លាយទៅជាសមាជិករបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។

បទបញ្ញត្តិទាំងឡាយណារបស់សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៅតាមរាជធានី ខេត្ត ត្រូវរៀបចំតាក់តែងឡើងដោយសាមីសមាគមផ្ទាល់ ហើយត្រូវអនុលោមតាមលក្ខន្តិកៈនេះ និងមិនអាចមានលក្ខណៈផ្ទុយទៅនឹងបទបញ្ញារបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ឡើយ។ ក្នុងករណីមានលក្ខណៈផ្ទុយគ្នា បទបញ្ញារបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់មានឧត្តមានុភាពលើបទបញ្ញារបស់សមាគមក្រុមប្រឹក្សាថ្នាក់ក្រុមប្រឹក្សាមូលដ្ឋាននៅតាមរាជធានី ខេត្ត។

### មាត្រា ៤៧.- គំរូលក្ខន្តិកៈរបស់សមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់នៅតាមរាជធានី ខេត្ត

គំរូលក្ខន្តិកៈរបស់សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៅរាជធានី ខេត្ត មានចែងក្នុងឧបសម្ព័ន្ធនៃលក្ខន្តិកៈរបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។

### មាត្រា ៤៨.- ត្រា និងរូបសញ្ញារបស់សមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់នៅតាមរាជធានី ខេត្ត

សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៅតាមរាជធានី ខេត្ត ត្រូវមានត្រានិងរូបសញ្ញាជាផ្លូវការរបស់ខ្លួន។ ត្រា និងរូបសញ្ញារបស់សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៅតាមរាជធានី ខេត្ត ត្រូវយកលំនាំតាមសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដោយគ្រាន់តែប្តូរឈ្មោះ និងអក្សរបំព្រួញឱ្យស្របតាមឈ្មោះរបស់សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៅតាមរាជធានី ខេត្ត នីមួយៗ។

## ជំពូកទី៨

## អន្តរប្បញ្ញត្តិ

### មាត្រា ៤៩.- ប្រតិភូចូលរួមមហាសន្និបាតលើកទីមួយ

ប្រតិភូចូលរួមក្នុងមហាសន្និបាតសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ លើកទីមួយ មានចំនួនយ៉ាងតិច ២២៥ រូប ដែលតំណាងឲ្យក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់នៅទូទាំងប្រទេស។

### មាត្រា ៥០.- ការពិនិត្យ និងកែសម្រួលសមាសភាពអភិបាលកិច្ចសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន

អាស្រ័យលើធនធានជាក់ស្តែងរបស់ខ្លួន សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ អាចពិចារណាកែសម្រួលសមាសភាពយន្តការអភិបាលកិច្ចរបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ឲ្យស្របតាមធនធានដែលខ្លួនមាន ដើម្បីធានាប្រសិទ្ធភាព និងនិរន្តរភាពរបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៅតាមរាជធានីខេត្ត។

### មាត្រា ៥១.- អគ្គលេខាធិការដ្ឋានសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន និងសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត

យោងតាមលិខិតរបស់ក្រសួងមហាផ្ទៃលេខ ១៤៩ សជណ ចុះថ្ងៃទី ២៨ ខែមករា ឆ្នាំ២០១៣ សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន និងសមាគមជាតិក្រុមប្រឹក្សារាជធានីខេត្ត មានអគ្គលេខាធិការដ្ឋានរួម ដែលមានឈ្មោះថា **អគ្គលេខាធិការដ្ឋានសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ** ។ អគ្គលេខាធិការដ្ឋាននេះ ត្រូវរៀបចំគោលនយោបាយ ប្រព័ន្ធ និងនីតិវិធីការងារសម្រាប់សមាគមទាំងពីរប្រភេទ។

អគ្គលេខាធិការដ្ឋានសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា មានអគ្គលេខាធិការមួយរូប និងអគ្គលេខាធិការរងមួយចំនួន។

# ជំពូកទី៩

# អវសានប្បញ្ញត្តិ

## មាត្រា ៥២.- និរាករណ៍នៃបទប្បញ្ញត្តិផ្សេងៗ

បទប្បញ្ញត្តិទាំងឡាយណារបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ដែលមានខ្លឹមសារផ្ទុយនឹងលក្ខន្តិកៈនេះ ត្រូវចាត់ទុកជានិរាករណ៍។

ក្នុងករណីលក្ខន្តិកៈសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ប្រតិសកម្ម ឬផ្ទុយនឹងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាមានអានុភាពលើលក្ខន្តិកៈរបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។

## មាត្រា ៥៣.-សុពលភាពគតិយុត្តិ

លក្ខន្តិកៈសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់នៅកម្ពុជា មានសុពលភាពគតិយុត្តិចាប់ ពីថ្ងៃមហាសន្និបាតអនុម័តជាផ្លូវការ។ ប្រធានសម្ព័ន្ធភាពជាតិ សមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់មានកាតព្វកិច្ចចុះហត្ថលេខាក្នុងភាពជាតំណាងនៃមហាសន្និបាតសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋានលើលក្ខន្តិកៈនេះ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០១៤

**ប្រធាន**

សយ គុសល

បានតម្កល់ទុកលក្ខន្តិកៈ ... ដែលបាន
ធ្វើវិសោធនកម្ម តាមលិខិតលេខ ...
ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ២០១៤
ភ្នំពេញ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ២០១៤
នាយកដ្ឋានកិច្ចការនយោបាយ
ប្រធាន